CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធនាគារ ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ ២០០៩ លេខ ០២

## ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា: ការកសាងកម្លាំងពលកម្មមានជំនាញ[១]

"ការអភិវឌ្ឍធនធានមនុស្ស... ជាដំណើរការមួយបន្តរហូត និងមិនមែនធ្វើភ្លាមបានភ្លាមទេ ។ ការងារនេះត្រូវការភាពសកម្មប្រយុទ្ធ ... និងរឹងមាំ ប៉ុន្តែក៏អាចបត់បែនបានងាយដែរ ដើម្បីសំរបទៅតាមការផ្លាស់ប្តូរក្នុងពិភពលោក និងបរិយាកាសសេដ្ឋកិច្ចក្នុងតំបន់ ... ព្រមទាំងបំផុសឱ្យមាន ការរំពឹងទុកដ៏ប្រាកដនិយមនានា ដែលត្រូវបំពេញឱ្យបាន ។"

*ប្រសាសន៍របស់ លោកស្រី **Sandra D'Amico** អគ្គលេខាធិការ របស់ **CAMFEBA** នៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩*

### វិបត្តិ និងធនធានពលកម្មកម្ពុជា: ផលប៉ះពាល់ និងចន្លោះខ្វះខាត

វិបត្តិបានស្តែងឲ្យឃើញពីចំនុចខ្សោយនៃសេដ្ឋកិច្ចកម្ពុជា ដូចជា កង្វះខាតកម្លាំងពលកម្មមានជំនាញជាដើម ។ ពលករកម្ពុជាភាគច្រើន ធ្វើការងារដែលត្រូវការជំនាញតិចតួច ជាពិសេសក្នុងវិស័យកសិកម្ម ប៉ុន្តែការងារបែបនេះ ក៏មាននៅ

**ក្រាហ្វិក ១: ការងារតាមមុខរបរ ឆ្នាំ២០០៤ (គិតជា %)**




ប្រភព : អង្កេតសេដ្ឋកិច្ច–សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤

ក្នុងវិស័យជំរុញកំណើនផ្សេងទៀត ដូចជា វិស័យកាត់ដេរ សំណង់ និងទេសចរណ៍ជាដើម ។ ផលិតភាពនៃកម្លាំងពលកម្មក្នុងវិស័យទាំងនោះ មានកំរិតទាប ថ្វីបើកំពុងកែលំអឡើងជាបណ្តើរៗក្តី ។ ដោយឡែកវិស័យឯកជន កំពុងជួបប្រទះកង្វះខាតកំលាំងពលកម្មជំនាញយ៉ាងធ្ងន់ធ្ងរ ។

កសិកម្ម ជាវិស័យសំខាន់បំផុតក្នុងការផ្តល់ឱកាសការងារនៅកម្ពុជា ។ ផ្អែកលើលទ្ធផលនៃ អង្កេតសេដ្ឋកិច្ច–សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤ កម្លាំងពលកម្មមានប្រមាណ ៧,៦លាននាក់ ឬជិត ៦០% នៃចំនួនប្រជាជនសរុបដែលរដ្ឋាភិបាលបានប៉ាន់ស្មាន នៅឆ្នាំនោះ ។ អង្កេតនេះបង្ហាញទៀតថា ក្នុងចំណោមកម្លាំងពលកម្ម ៧,៦លាននាក់ មាន ៧,៥លាននាក់ មានការងារធ្វើ ដោយក្នុងនោះ មាន ៦៣% ធ្វើការក្នុងវិស័យកសិកម្ម និងនេសាទ ហើយអ្នកនៅសល់ពីនោះ ភាគច្រើនធ្វើការងារដែលត្រូវការជំនាញតិចតួច ដូចជា ការលក់ដូរ និងសិប្បកម្ម ជាដើម (ក្រាហ្វិក ១) ។ វិស័យកសិកម្ម ស្រូបយកកម្លាំងពលកម្មអស់ជិតពីរភាគបី ក៏ពិតមែន ប៉ុន្តែចូលរួមចំណែកបានមិនដល់ មួយភាគបីនៃ ផលិតផលក្នុងស្រុកសរុប (ផសស) នោះទេ ។ តាំងពីដើមរៀងមក ការចូលរួមចំណែកនៃវិស័យកសិកម្មក្នុងកំណើន ផសស មានកំរិតមិនទៀងទាត់សោះ ហើយពេលខ្លះមានតួលេខអវិជ្ជមានទៀតផង ។ ក្នុងវិស័យកសិកម្ម ពលករភាគច្រើន (៥២%) ធ្វើការឲ្យគ្រួសាររបស់ខ្លួនដោយគ្មានប្រាក់កំរៃ ហើយមានប្រហែល ២៩% ប្រកបមុខរបរខ្លួនឯង និងមានត្រឹមតែ ១៧% ប៉ុណ្ណោះ ដែលធ្វើការឲ្យគេយកប្រាក់កំរៃ ។

ទិន្នន័យបូកសរុបថ្មីៗរបស់ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និង ផែនការអភិវឌ្ឍការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញ បានបង្ហាញពី ការបន្តមានលំនាំការងារដូចខាងលើ ។ ផ្អែកលើទិន្នន័យនេះ ក្នុងឆ្នាំ២០០៨ មានពលករប្រមាណ ៣,២លាននាក់ ក្នុងវិស័យកសិកម្ម ធៀបនឹងត្រឹមតែ ២៣២.០០០នាក់ក្នុងវិស័យកាត់ដេរ

១ អត្ថបទនេះ ជាការបូកសរុបបទបង្ហាញ និងការពិភាក្សាផ្សេងៗក្នុងវគ្គទី២ នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។ វាគ្មិនក្នុងវគ្គនេះរួមមាន: ឯកឧត្តម ហេង សួរ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង លោកស្រី Sandra D'Amico អគ្គលេខាធិការនៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) ។

* ផ្អែកលើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

១៣៩.០០០នាក់ក្នុងវិស័យសំណង់និងរ៉ែ និង ៥៨.០០០នាក់ក្នុងឧស្សាហកម្មផលិតផ្សេងៗទៀត ។

នៅកម្ពុជា វិស័យកាត់ដេរ និងសំណង់ ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិសាកល ដោយចំនួនអ្នកបាត់បង់ការងារ រឺអ្នកមានការងារធ្វើមិនពេញលេញបានកើនឡើង ។ ការវាយតម្លៃភ្លាមៗមួយរបស់ វិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ បានបង្ហាញថា ការបិទទ្វាររោងចក្រ ឬការកាត់បន្ថយចំណាយប្រតិបត្តិការក្នុងឧស្សាហកម្មកាត់ដេរ បានធ្វើឲ្យបាត់បង់ការងារ ចំនួន ២៧.០០០ ក្នុងឆ្នាំ ២០០៨ និង ១៩.០០០ បន្ថែមទៀត មកដល់ដើមខែមីនាក្នុងឆ្នាំនេះ ។ ចំនួនម៉ោងធ្វើការធម្មតា និងចំនួនម៉ោងធ្វើការបន្ថែម បានថយចុះ និងមានការកាត់បន្ថយរយៈពេលនៃកិច្ចសន្យាការងារ ការពន្យាពេលបើកប្រាក់ឈ្នួល និងការលាឈប់ដោយស្ម័គ្រចិត្ត ។ ស្ថានភាពបែបនេះ បណ្តាលឲ្យបាត់បង់ ឬធ្លាក់ចុះប្រាក់ចំណូល ដែលមានកំរិតជាមធ្យម ៨០ដុល្លារក្នុងមួយខែ ។ ក្នុងវិស័យសំណង់ ការវាយតម្លៃដដែលនេះបង្ហាញថា ការងារចំនួន ៣៦.៥០០ បានបាត់បង់នៅក្នុងឆ្នាំ២០០៨ និង ២៥.៦០០ ថែមទៀតមកដល់ដើមខែមីនា ២០០៩ ។ កម្មករសំណង់ ជាមធ្យមរកចំណូលបាន ១០០ដុល្លារ ក្នុងមួយខែ ។

ផ្ទុយទៅវិញ វិស័យទេសចរណ៍ និងកសិកម្ម ត្រូវបានចាត់ទុកជាវិស័យទ្រនាប់សំរាប់ជួយទប់ទល់ ដោយបានផ្តល់ការងារជាច្រើន។ ការសិក្សាខាងលើនេះបង្ហាញថា វិស័យទេសចរណ៍ផ្តល់ការងារបានចំនួន ១៦.៦១៤ នៅក្នុងឆ្នាំ២០០៨ និង ១២.៦៩៨ ទៀត មកដល់ដើមខែមីនា ២០០៩ ។ ប៉ុន្តែ ក៏មានការកាត់បន្ថយចំនួនម៉ោងធ្វើការ និងការថយចុះសកម្មភាពធម្មតាអស់មួយចំនួនដែរ ។ ចំណុចគួរកត់សំគាល់គឺក្នុងអំឡុងពេលដដែលនេះ វិស័យកសិកម្ម បានផ្តល់ការងារដល់ពលករចំនួន ៦៥០.០០០នាក់ និង ២០៣.២០០នាក់ ។ តួលេខដ៏ធំនេះបង្ហាញពីសារៈសំខាន់នៃវិស័យកសិកម្ម ក្នុងការផ្តល់ការងារ ។ ដោយសារវិស័យកសិកម្មនៅកម្ពុជា ត្រូវការជំនាញតិចតួច ហេតុនេះអ្នកដែលបាត់បង់ការងារនៅក្នុងវិស័យផ្សេងៗ អាចប្តូរមកបំពេញការងារខាងកសិកម្មបានយ៉ាងងាយ ។ កម្មករកាត់ដេរ និងកម្មករសំណង់ភាគច្រើន ជាជនចំណាកស្រុក ពីទីជនបទ ដូច្នេះនៅពេលបាត់បង់ការងារ ពួកគេភាគច្រើនគ្មានជំរើសអ្វីក្រៅពីវិលត្រលប់ទៅភូមិកំណើត និងស្វែងរកការងារ ខាងស្រែចំការនោះទេ ។ នៅកម្ពុជា ពលករក្នុងវិស័យកសិកម្ម រកចំណូលបានជាមធ្យម ៥០ដុល្លារប៉ុណ្ណោះក្នុងមួយខែ គឺទាបជាខ្លាំង បើធៀបនឹងប្រាក់ឈ្នួលក្នុងវិស័យផ្សេងៗទៀត ។

ដើម្បីស្វែងយល់ពីកង្វះខាតកម្លាំងពលកម្មមានជំនាញ និងកំរិតអប់រំខ្ពស់នៅកម្ពុជា យើងត្រូវពិនិត្យមើលពីប្រព័ន្ធអប់រំនៅក្នុងប្រទេស ។ ប្រព័ន្ធអប់រំនៅកម្ពុជា មាន ៣ផ្នែកៈ ប្រព័ន្ធអប់រំទូទៅ (ការអប់រំចាំបាច់សំរាប់ប្រជាពលរដ្ឋគ្រប់រូប) ប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញ (technical and vocational education and training-TVET) និងប្រព័ន្ធអប់រំកំរិតខ្ពស់ ។ ផ្អែកតាមតួលេខរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងឆ្នាំសិក្សា ២០០៧-២០០៨ ប្រព័ន្ធអប់រំកំរិតខ្ពស់ មាននិស្សិតចំនួន ១១០.០០០នាក់ ធៀបនឹង ៩២.០០០នាក់ក្នុងឆ្នាំសិក្សា២០០៦-២០០៧ ។ ម្យ៉ាងទៀត មាននិស្សិតចំនួន ៤.៤០០នាក់ បានបញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញ នៅក្នុងឆ្នាំ២០០៧ ។ ប្រព័ន្ធ *TVET* ស្ថិតក្នុងដំណាក់កាលក្មេងខ្ចី ប៉ុន្តែវាមានប្រយោជន៍ច្បាស់ណាស់សំរាប់ការស្វែងរកការងារ និងបង្កើនប្រាក់ចំណូល ជាពិសេសចំពោះប្រជាពលរដ្ឋក្រីក្រ ដែលមិនមានលទ្ធភាពរៀនដល់កំរិតខ្ពស់ៗ ។ លទ្ធផលនៃអង្កេតបង្ហាញថា សិស្សដែលបានចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ អាចបង្កីនប្រាក់ចំណូលប្រហែល ៣៥% ។

បញ្ហាប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញ និងប្រព័ន្ធអប់រំកំរិតខ្ពស់ កំពុងបំពេញតាមតំរូវការទីផ្សារពលកម្ម ឬក៏អត់ ក៏ត្រូវពិនិត្យមើលផងដែរ ។ គេត្រូវវាយតម្លៃថា តើប្រព័ន្ធអប់រំកំពុងផ្តល់នូវជំនាញសំខាន់ៗសំរាប់អោយយុវជនមានសមត្ថភាព ធ្វើការងារបានរឺយ៉ាងណា ។ ប្រព័ន្ធអប់រំគួរមានការកែប្រែថ្មីៗសមស្រប ដើម្បីជួយជំរុញដល់សកម្មភាពពាណិជ្ជកម្មថ្មីៗ មិនមែនផ្តោតលើតែសកម្មភាពពាណិជ្ជកម្ម ដែលមានកម្លាំងពលកម្មសំបូរហូរហៀររួចហើយនោះទេ (ដូចជាខាង អ៊ុតសក់ កាត់ដេរសម្លៀកបំពាក់ ជួសជុលម៉ាស៊ីន) ។ ក្រៅពីនេះក៏អាចមានបញ្ហាបណ្តុះបណ្តាលជំនាញដដែលជាន់គ្នា នៅក្នុងប្រព័ន្ធទាំងនោះដែរ ។

សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (*Cambodian Federation of Employers and Business Associations-CAMFEBA*) បានធ្វើការសិក្សាពីទីផ្សារជាលើកទី១ នៅខែមិថុនា ២០០៨ ដើម្បីកំណត់មើលពីភាពមិនស៊ីគ្នារវាង ជំនាញដែលមានជាក់ស្តែងក្នុងទីផ្សារពលកម្ម និងជំនាញដែលនិយោជកកំពុងស្វែងរក ។ ការសិក្សានេះបានធ្វើអង្កេតលើ ពួកយុវជន ចំនួន ២.១៩៤នាក់ និង និយោជកក្នុងវិស័យផ្សេងៗគ្នា ចំនួន ២២០នាក់ ។

## ក្រាហ្វិក ២: ជំនាញមានតំរូវការ

### តាមទស្សនៈនិយោជក




### តាមទស្សនៈយុវជន




ក្រាហ្វិក១តំណាងឲ្យចម្លើយរបស់និយោជកចំពោះសំណួរ "តើជំនាញអ្វីពិបាករកជាងគេបំផុត?" ចំណែកឯ ក្រាហ្វិក២ តំណាងឲ្យចម្លើយរបស់យុវជនលើសំណួរ "តើត្រូវមានជំនាញអ្វីថែមទៀតដើម្បីរកការងារបានល្អ?"

ប្រភព: ការសិក្សាពីទីផ្សាររបស់សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា

## ការសិក្សារបស់ CAMFEBA បានរកឃើញថា:

- និយោជកបញ្ជាក់ថា "ជំនាញទន់ (*soft skill*)" ដូចជា ជំនាញធ្វើសេចក្តីសម្រេចចិត្ត ជំនាញដោះស្រាយបញ្ហា និង ឥរិយាបថត្រឹមត្រូវ គឺជាជំនាញសំខាន់ៗបំផុតដែលកំពុងខ្វះខាតនៅក្នុងទីផ្សារពលកម្មបច្ចុប្បន្ន និងដែលពួកនិយោជក ចង់ឲ្យមានការរីកចំរើនឡើង ។ ចំពោះយុវជនវិញ ពួកគេបែរជាយល់ថា ភាសាបរទេស និងជំនាញកុំព្យូទ័រ ជាជំនាញសំខាន់ដែលខ្លួនត្រូវរៀន ដើម្បីអាចស្វែងរកការងារល្អបាន ។ ចំពោះសំណួរថា "តើជំនាញអ្វីពិបាករកបំផុត?" និយោជក ៥២% ឆ្លើយថា "ឥរិយាបថការងារ" និង ៣៧% ទៀតឆ្លើយថា ភាសាបរទេស ។ ចំពោះសំណួរ "តើការបណ្តុះបណ្តាលប្រភេទណា គួរផ្តល់អាទិភាព?" និយោជក ៣៩% ឆ្លើយថា ការបណ្តុះបណ្តាលលើ ជំនាញធ្វើសេចក្តីសម្រេចចិត្ត និងដោះស្រាយបញ្ហា ធៀបនឹង ២៧% លើជំនាញភាសាបរទេស និង ៩% លើជំនាញកុំព្យូទ័រ ។ រីឯសំណួរថា "តើអ្នកចង់ជួយណែនាំអ្វីដល់ពួកយុវជន?" និយោជក ៧៧% ឆ្លើយថា "ត្រូវកសាងឥរិយាបថត្រឹមត្រូវ" ។

- យុវជនភាគច្រើនជឿថា សញ្ញាប័ត្រថ្នាក់ឧត្តមសិក្សាសំខាន់ណាស់ ហេតុនេះក៏ចង់បានវាមួយ ។ ប៉ុន្តែដោយសារ កំហិតផ្នែកហិរញ្ញវត្ថុ ពួកគេជាច្រើននាក់មិនអាចសម្រេចសេចក្តីប្រាថ្នានេះទេ ។ សិស្សវិទ្យាល័យមួយចំនួនគ្មានជំរើសអ្វីក្រៅពីស្វែងរកការងារធ្វើភ្លាមៗ បន្ទាប់ពីទទួលបានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ។

- ការចូលទៅក្នុងទីផ្សារពលកម្ម និងប្រកួតប្រជែងជាមួយនឹងអ្នកស្វែងរកការងារជាច្រើននាក់ទៀត គឺជាការលំបាកមួយ ដោយសារកង្វះចំណេះដឹងស្តីពីវិធីស្វែងរកការងារធ្វើ កង្វះប្រភពព័ត៌មានទាក់ទងនឹងការងារ ការលំបាករកបានបទពិសោធន៍ដំបូងក្នុងការងារ និងកង្វះជំនាញដែលនិយោជកត្រូវការ ។

- នៅក្នុងអង្កេត និយោជក និងយុវជនភាគច្រើន បានស្នើអោយរដ្ឋាភិបាល និងស្ថាប័នអប់រំនានា ពិចារណាពីវិធានការមួយចំនួនដូចតទៅ: ការលើកកំពស់ស្តង់ដារអប់រំ និងប្រព័ន្ធទទួលស្គាល់គុណភាព ការផ្តល់គ្រូមានគុណសម្បត្តិគ្រប់គ្រាន់ឲ្យបានច្រើនថែមទៀត ការកែលំអកម្មវិធីសិក្សា និងសំភារៈបរិក្ខារសាលារៀន ទំនាក់ទំនងកាន់តែប្រសើររវាងអ្នកអប់រំ និយោជក និងរដ្ឋាភិបាល ព្រមទាំង ការផ្តោតលើទ្រឹស្តីតិចជាងមុន និងលើជំនាញអនុវត្តជាក់ស្តែងច្រើនជាងមុន។

ការសិក្សាមួយស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំកំរិតខ្ពស់នៅកម្ពុជា ជិតបានចប់សព្វគ្រប់ហើយ ។ ផ្អែកលើ លទ្ធផលដំបូងនៃការសិក្សានេះ បញ្ហាប្រឈមសំខាន់ៗបំផុតចំពោះស្ថាប័នអប់រំនៅកម្ពុជា មានជាអាទិ:

- ការស្វែងរកសាស្ត្រាចារ្យមានសមត្ថភាពគ្រប់គ្រាន់
- ការពង្រឹងកិច្ចសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានា (ក្នុងការអភិវឌ្ឍន៍វិស័យអប់រំ)
- ការកសាងទំនាក់ទំនងជាមួយវិស័យឧស្សាហកម្ម
- ការកែលំអហេដ្ឋារចនាសម្ព័ន្ធអប់រំ
- ការរៀបចំកម្មវិធីសិក្សាឲ្យបានសមស្របតាមតំរូវការរបស់និយោជក
- ការផ្តល់ការបណ្តុះបណ្តាលបន្ថែម និង
- ការសិក្សាស្រាវជ្រាវពីតំរូវការទីផ្សារពលកម្ម

តាមរយៈលទ្ធផលនេះ គេអាចសន្និដ្ឋានថា បញ្ហាប្រឈមក្នុងវិស័យអប់រំ មិនមែនជាប់ទាក់ទងជាមួយតែកម្មវិធីសិក្សា និងប្រភេទវគ្គសិក្សាដែលបានផ្តល់នោះទេ ប៉ុន្តែវាទាក់ទងមួយភាគធំផងដែរទៅនឹង វិធីសាស្ត្រនៃការបង្រៀន ។

## វិបត្តិ និងមធ្យោបាយឆ្ពោះទៅមុខៈ ចក្ខុវិស័យ និងទិសដៅគោលនយោបាយនៅអនាគត

ប្រជាជនកម្ពុជា កំពុងកើនឡើងយ៉ាងលឿន ដោយគេព្យាករណ៍ថា នឹងឡើងដល់ ១៧លាននាក់ នៅឆ្នាំ២០១១ ។ ដូច្នេះ នឹងមានយុវជនកាន់តែច្រើនចូលខ្លួនទៅក្នុងកំលាំងពលកម្ម គឺដូចគ្នានឹងកំណើនកម្លាំងពលកម្មនាពេលថ្មីៗ និងក្នុងប៉ុន្មានឆ្នាំខាងមុខ ដោយសារពួកយុវជនដែលបានកើតនៅអំឡុងពេលមានអត្រាកំណើតខ្ពស់ក្នុងទសវត្សរ៍ ១៩៨០ ។ លក្ខណៈប្រជាសាស្ត្រនេះ ចង្អុលបង្ហាញពីតំរូវការការអភិវឌ្ឍធនធានមនុស្ស ពីព្រោះត្រូវមានកម្លាំងពលកម្មមានជំនាញខ្ពស់ ដើម្បីសំរេចបានកំណើនសេដ្ឋកិច្ចល្អវិសេសដូចពីមុនទៀត ព្រមទាំងមាន សមត្ថភាពប្រកួតប្រជែងខ្លាំងក្នុងវិស័យសំខាន់ៗដែលជំរុញកំណើន ។

ការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា ជាដំណើរការមួយបន្តរហូត និងត្រូវមានទិន្នន័យត្រឹមត្រូវ ។ ការយល់ដឹងពីជំនាញមានតំរូវការខ្ពស់ក្នុងពេលសព្វថ្ងៃ និងទៅអនាគត គឺសំខាន់ខ្លាំងណាស់ ។ ដូច្នេះ គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវមានលក្ខណៈសកម្មប្រយុទ្ធ មិនមែនគ្រាន់តែឆ្លើយតបនឹងតំរូវការជាក់ស្តែងនោះទេ និងត្រូវអាចបត់បែនបាន ទៅតាមបរិយាកាសកំពុងផ្លាស់ប្តូរ និងសាកលភាវូបនីយកម្ម ព្រមទាំងមានលក្ខណៈប្រាកដនិយមផង ។

ចំណុចសំខាន់ដូចគ្នាមួយទៀតគឺត្រូវធានាថា ការផ្គត់ផ្គង់ការងារ គឺអាចបំពេញបានតាមតំរូវការការងារ និងតំរូវការជំនាញកំរិតខ្ពស់ដែលគោលនយោបាយកំពុងព្យាយាមកសាងឡើងនៅក្នុងកម្លាំងពលកម្ម ។ គេត្រូវឧបត្ថម្ភគាំទ្រដល់ការពង្រីកវិស័យឧស្សាហកម្ម និងសេវាកម្ម ដើម្បីស្រូបយកពីវិស័យកសិកម្មនូវពួកពលករដែលបានអភិវឌ្ឍជំនាញ និងកំរិតសិក្សារួចហើយ ។ ការវិនិយោគលើការផ្តួចផ្តើមទ្រង់ទ្រាយធំៗរបស់រដ្ឋាភិបាល ដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏អាចជួយស្រូបយកពលករដូចគ្នា ។ ចំណុចសំខាន់ គឺ កម្លាំងពលកម្មដែលមានកំរិតអប់រំ និងជំនាញខ្ពស់ៗ នឹងគ្មានប្រយោជន៍អ្វីឡើយ ប្រសិនបើមិនមានឱកាសការងារដ៏សមស្របនៅក្នុងទីផ្សារពលកម្ម ។ ឱកាសការងារនៅក្រៅប្រទេសសំរាប់ប្រជាពលរដ្ឋកម្ពុជា ភាគច្រើនជាប្រភេទការងារត្រូវការជំនាញតិចតួច ដូចជា ការងារក្នុងវិស័យកសិកម្ម និងការងារតាមផ្ទះ ។ ប៉ុន្តែតំរូវការពីក្រៅប្រទេសនូវពលករកម្ពុជាដែលមានជំនាញវិជ្ជាជីវៈ នឹងកើនឡើងភ្លាម ប្រសិនបើកម្ពុជាអាចបណ្តុះបណ្តាលជនប្រភេទនេះបានកាន់តែច្រើន ។

បញ្ហាចោទលើវិស័យជំរុញកំណើននានានៅកម្ពុជា គឺ វិស័យទាំងនេះផ្តោតជាសំខាន់តែលើសកម្មភាពផលិតកម្មសាមញ្ញៗ ដែលត្រូវការតែពលករមានជំនាញតិចតួច ។ ដូច្នេះដើម្បីបំពេញតំរូវការការងាររបស់ពលករមានជំនាញខ្ពស់ៗ វិស័យកាត់ដេរ សំណង់ ទេសចរណ៍ និងកសិកម្មនៅកម្ពុជា ត្រូវតែអភិវឌ្ឍន៍

ខ្លួនឲ្យមានសកម្មភាពផលិតកម្ម ដែលប្រើបច្ចេកទេសកំរិតខ្ពស់ដែរ ។

ភាពខុសគ្នាតិចតួចរវាងប្រាក់ចំណូលក្នុងវិស័យកសិកម្ម និង ប្រាក់ចំណូលក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម មិនបានលើកទឹកចិត្តអ្វីច្រើនដល់ពលករក្នុងវិស័យកសិកម្ម ឲ្យអភិវឌ្ឍកំរិតជំនាញរបស់ខ្លួនឡើងទៀតនោះទេ ។ ដូច្នេះ ត្រូវតែពិនិត្យមើលពីភាពសមស្របនៃស្តង់ដារប្រាក់បៀវត្សរ៍នាពេលបច្ចុប្បន្ន ។

ចំពោះប្រព័ន្ធអប់រំទាំងមូល ដើម្បីឲ្យវាក្លាយជាកំលាំងជំរុញដល់ការអភិវឌ្ឍធនធានមនុស្ស គេត្រូវអនុវត្តវិធានការ មួយចំនួនដូចខាងក្រោម ដើម្បីលើកកម្ពស់ទាំងបរិមាណ និងគុណភាព នៃការអប់រំ:

- ការរចនាតាក់តែងកម្មវិធីសិក្សា ដោយពិចារណាទៅលើតំរូវការនៃទីផ្សារពលកម្ម
- ការសម្របសម្រួល និងធ្វើស្តង់ដារូបនីយកម្ម នៃកម្មវិធីសិក្សា
- ការផ្តោតលើជំនាញមូលដ្ឋានគោល ដែលកំពុងខ្វះខាតក្នុងទីផ្សារពលកម្មនាពេលបច្ចុប្បន្ន ដូចជា ឥរិយាបថការងារត្រឹមត្រូវ ជំនាញដោះស្រាយបញ្ហា និង ការធ្វើសេចក្តីសម្រេចចិត្ត
- ការជ្រើសរើសគ្រូមានសមត្ថភាពគ្រប់គ្រាន់ឲ្យបានច្រើនជាងមុន
- ការដំឡើងប្រាក់បៀវត្សរ៍គ្រូបង្រៀន
- ការបង្កើតក្រុមប្រឹក្សាយោបល់ក្នុងសាលា ដើម្បីបំពេញការងារផ្សព្វផ្សាយព័ត៌មានស្តីពីឱកាសការងារ និងបញ្ហាផ្សេងៗ ទាក់ទងនឹងឱកាសការងារដល់សិស្ស–និស្សិត
- ការអនុវត្តន៍វិធានការថ្មីៗទៀត ដើម្បីរៀបចំឲ្យសិស្ស–និស្សិតចូលរួមក្នុងវិស័យការងារ (ដូចជា ដំណើរទស្សនកិច្ចសិក្សា និងឱកាសហាត់ការនៅតាមបណ្តាក្រុមហ៊ុន)
- ការផ្តល់បរិក្ខារសិក្សាជាមូលដ្ឋាន ដូចជាកុំព្យូទ័រ ជាដើម ដើម្បីបង្កើនលទ្ធភាពទទួលបានព័ត៌មាន ស្តីពីទីផ្សារពលកម្ម
- ការយកចិត្តទុកដាក់បន្ថែមទៅលើការអភិវឌ្ឍន៍ការអប់រំនៅតាមបណ្តាខេត្ត ដោយផ្សារភ្ជាប់ទៅនឹងតំរូវការនៃ ផែនការពិពិធកម្មសេដ្ឋកិច្ច
- អភិវឌ្ឍសមាគម និងបណ្តាញទំនាក់ទំនងយុវជន
- ការពង្រីងចំណងទាក់ទងនានា ដោយបង្កើនភាពជាដៃគូរវាងវិស័យឯកជន–សាធារណៈ ជាពិសេសក្នុងប្រព័ន្ធ *TVET*
- ការបង្កើតទីភ្នាក់ងារជាតិស្វែងរកការងារ និងត្រួតពិនិត្យស្តង់ដារសមត្ថភាព
- ការបង្កើនសកម្មភាពគណៈកម្មាធិការសម្របសម្រួលនៃរដ្ឋាភិបាល ដូចជា ក្រុមប្រឹក្សាជាតិស្តីពីការបណ្តុះបណ្តាល និង ការបង្កើតក្រុមការងារលើវិស័យឯកជនទី៩ ដើម្បីដោះស្រាយបញ្ហាអប់រំ និងកសាងទំនាក់ទំនងរវាងវិស័យឯកជន រដ្ឋាភិបាល និងស្ថាប័នអប់រំ ។

វិធានការនានាដូចខាងក្រោម អាចជួយដល់ប្រព័ន្ធ *TVET* ឲ្យវិវត្តកាន់តែប្រសើរថ្លង់ផុតពីដំណាក់កាលក្មេងខ្ចី:

- ផ្តល់អាទិភាពដល់វិស័យឧស្សាហកម្ម ដោយផ្អែកលើកំណើនសេដ្ឋកិច្ច និងអ្វីដែលមានស្រាប់
- លើកកម្ពស់ការបណ្តុះបណ្តាលជំនាញខាងធ្វើជំនួញ ប៉ុន្តែផ្តោតទៅលើវិស័យថ្មីៗ ជាជាងលើវិស័យដែលមាន ធនធានមនុស្សពេញពោររួចទៅហើយ ។
- សម្របសម្រួល និងពង្រីងកម្មវិធីសិក្សានាពេលបច្ចុប្បន្ន ព្រមទាំងធ្វើបច្ចុប្បន្នភាពឲ្យស្របតាមតំរូវការវិស័យឯកជន
- កែលំអវិធានធានាគុណភាព ជាមួយនិងការអភិវឌ្ឍន៍កម្មវិធីសិក្សា
- ធានាថា កាលវិភាគមានលក្ខណៈអាចបត់បែនបានគ្រប់គ្រាន់ ដើម្បីឲ្យសិស្សនិស្សិតអាចរៀនសូត្រផង និងធ្វើការរកចំណូលបានផង
- ដាក់អនុវត្តយុទ្ធសាស្ត្រម៉ាឃីតទីងមួយ សំរាប់ប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញ
- ដោះស្រាយបញ្ហាថវិកា និងតំរូវការសំភារៈបរិក្ខារបង្រៀនសំបូរបែប
- បង្កើនចំនួនគ្រូបង្រៀន/អ្នកបណ្តុះបណ្តាល និងសំរបសំរួលជាមួយវិស័យឯកជន សំរាប់ការអញ្ជើញឲ្យចូលរួមធ្វើបទបង្ហាញសំរាប់សិស្ស–និស្សិត
- កសាងទំនាក់ទំនងភាពជាដៃគូជាមួយវិស័យឯកជនបន្ថែមទៀត

ដើម្បីជួយបំពេញតាមតំរូវការទីផ្សារពលកម្ម មានការប៉ាន់ស្មានថា ប្រព័ន្ធ *TVET* ត្រូវមាននិស្សិតបញ្ចប់ការសិក្សាចំនួន ១៦.១៤៤នាក់នៅឆ្នាំ២០១២, ១៥.៨៧៥នាក់នៅឆ្នាំ២០១៣, ១៨.០៤៨នាក់នៅឆ្នាំ២០១៤ និង ១៩.០០៥នាក់នៅឆ្នាំ ២០១៥ ។

តាមរយៈស្ថាប័នគ្រប់គ្រងការបណ្តុះបណ្តាលវិជ្ជាជីវៈ (ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) រដ្ឋាភិបាលកំពុងពិចារណាលើសកម្មភាពខាងគោលនយោបាយមួយចំនួនដូចខាងក្រោម:

- កែលំអប្រតិបត្តិការរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និង ស្វែងរកវិធីដើម្បីបង្កើនកញ្ចប់ថវិកា (ដូចជា ការគាំទ្ររបស់ម្ចាស់ជំនួយ)
- កែលំអការបណ្តុះបណ្តាលរបស់សាស្ត្រាចារ្យ
- បង្កើនគុណភាពការបណ្តុះបណ្តាលស្តីពី សកម្មភាពក្រោយពេលប្រមូលផល និងសកម្មភាពកសិកម្មផ្សេងទៀត
- បង្កើតមជ្ឈមណ្ឌលការងារ នៅតាមទីតាំងសំខាន់ៗ (ដូចជា រាជធានីភ្នំពេញ សៀមរាប បាត់ដំបង)
- បង្កើតក្របខ័ណ្ឌវិនិច្ឆ័យសមត្ថភាព ដើម្បីជួយសំរួលដល់ដំណើរការចុះឈ្មោះចូលរៀនថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ

វិបត្តិសេដ្ឋកិច្ច បានផ្តល់ឱកាសដ៏ល្អវិសេសមួយដល់កម្ពុជា ដើម្បីពិនិត្យឲ្យបានកាន់តែល្អិតល្អន់ ពីសមត្ថភាពប្រកួតប្រជែង នៃកម្លាំងពលកម្មនាពេលបច្ចុប្បន្ន ព្រមទាំងប្រភេទជំនាញដែលទីផ្សារពលកម្មត្រូវការ ។ ចំនុចសំខាន់គួរចងចាំទុក គឺការអភិវឌ្ឍធនធានមនុស្ស វាជាសមាសភាគដ៏ចាំបាច់សំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច ហើយការអភិវឌ្ឍសេដ្ឋកិច្ច ក៏ជាសមាសភាគដ៏ចាំបាច់សំរាប់ការអភិវឌ្ឍធនធានមនុស្សដូចគ្នា ។

**CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា ✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdrimail@online.com.kh, website: http://www.cdri.org.kh